# ក្បួនដោះទ័លក្រ

រៀបរៀងដោយ **ហាក់-ឆៃហុក**



ណ្ណាល័យ
29
ប្បុរា
សិទ្ធិ ១៩៩៨

**បើចង់កុំឲ្យក្រ ទាល់តែមានក្បួនដោះទ័លក្រ**

www.elibraryofcambodia.org

សុំចម្លងពីលោក ហៅ ឃុនសំរិទ្ធ ដល់កម្ពុជាខ្មែរ
ដើម្បីទុកដំកល់ក្នុង elibrary of Cambodia.
កក្កដា 2015

# ក្បួនដោះអំពើធ្មប់


រៀបរៀងដោយ

លោក ហាក់-ឆៃហុក

(សមាជិកសមាគមអ្នកនិពន្ធខ្មែរ)



បោះពុម្ពផ្សាយដោយ

បណ្ណាគារ អប្សរា

បោះពុម្ពលើកទី១



រក្សាសិទ្ធិ



ព.ស. ២៥១៩ គ.ស. ១៩៧៥



www.elibraryofcambodia.org

# មាតិការឿង


**វគ្គទី១**

គ្រប់គ្នាមិនចង់ក្រ ប៉ុន្តែហេតុអ្វីបានជាក្រ?

**វគ្គទី២**

យើងត្រូវដំណោះទ័លដោយវិធីណា?

**វគ្គទី៣**

សេចក្តីពេញចិត្តក្នុងកិច្ចការងារជាផ្លូវនៃសេចក្តីសុខ ។

**វគ្គទី៤**

គ្រប់គ្នារមែងមានសេរីភាពស្មើគ្នាទាំងអស់ !

**វគ្គទី៥**

ចូរព្រមក្រកាយ តែកុំព្រមក្រចិត្ត !

**វគ្គទី៦**

ការចេះមែន ធ្វើមែនក៏ជាថ្នាំដោះទ័លក្របានដែរ ។

**វគ្គទី៧**

គន្លឹះពិសេសសំរាប់ការដោះទ័លក្រ

ពាក្យបរិយាយចុងក្រោយ


www.elibraryofcambodia.org

# អារម្ភកថា

ក្នុងកាលៈទេសៈស្រុកកើតសង្គ្រាមដូចសព្វថ្ងៃនេះ បើទុកជាគ្មានក្បួនខ្នាតនិយាយពីរឿងក្រ ដើម្បីយើងស្គាល់ថាក្រមានរសជាតិដូចម្តេច ក៏យើងរាល់គ្នាស្គាល់ច្បាស់ជាងថ្ងៃទៅទៀត ពីព្រោះយើងម្នាក់ៗបានបរិភោគមេរោគក្ររួចហើយបួនឆ្នាំ ឡើងកាងពោះត្រលុកៗសល់តែស្បែកដណ្តប់ឆ្អឹង? ចំណែកអ្នកមានបានដោយសារសង្គ្រាមក៏មានគួរដែរ ប៉ុន្តែកុំនិយាយពីគេអី ពីព្រោះអស់លោកហ្នឹងមិនមែន **កនយើង** ភាគច្រើនទេ !

បុព្វហេតុដែលនាំឱ្យខ្ញុំរពិសដៃចងក្រង ក្បួនដោះទ័លក្រនេះឡើង ដោយខ្ញុំយោលទៅលើកត្តាបី ដែលយើងជួនកាលភ្លេចខ្លួនមិនដឹងថាយើងក្រមកពីអ្វី គឺ ÷

១- ការមិនចុះសំរុងនឹងជីវិត

២- មិនដឹងគន្លឹះនៃការដោះទ័លក្រ

៣- ខំរកស៊ីដែរតែចៀសក្រមិនផុត

www.elibraryofcambodia.org

បើអស់លោកអ្នកបានធ្វើដំណោះស្រាយតាមក្បួននេះ ខ្ញុំជឿជាក់ថា អស់លោកអ្នកមុខជាចៀសផុតពីសេចក្តីក្រ (ក្រអត់កន្ទបវ័ណ្ណ) ជាពុំខាន ។

ចូរជោគជ័យសិរីមង្គល មានដល់អ្នកអានគ្រប់ៗគ្នា ។

ភ្នំពេញ, ថ្ងៃទី ០១ មករា ១៩៧៥

**ហាក់ ឆៃហុក**

www.elibraryofcambodia.org

# វគ្គទី១

# គ្រប់គ្នាមិនចង់ក្រ ប៉ុន្តែហេតុអ្វីបានជាក្រ?

ឡើងឈ្មោះថា សេចក្តីទីទ័លក្រហើយ អ្នកណាៗ ក៏មិនចង់ជួបចង់ប្រទះដែរ ប៉ុន្តែហេតុអ្វីទើបបានជាមនុស្ស ទីទ័លក្រយ៉ាងច្រើនទៅវិញ? ខនេះជាបញ្ហាគួរឱ្យយើង គិតខ្លាំងណាស់ ប្រៀបដូចសក់មួយសរសៃដែលបាំងភ្នំ មួយជិត បើយើងគិតចេញដំណោះពីរឿងទ័លក្រ ក៏ចេញ ផុតផុតរហូតដែរ អស់លោកអ្នកនឹងលែងជួបប្រទះ ពីរឿង ទ័លក្រតទៅទៀតអស់មួយជីវិត ។ សេចក្តីប្រាថ្នាច្រើន ពេកទៅមិនចេះស្កប់ ស្កាបក្នុងកម្លាំងរបស់ខ្លួនហ្នឹងហើយ ជាកត្តាសំខាន់ ដែលធ្វើឱ្យមនុស្សភាគច្រើនត្រូវភ្ជាក់ខ្លួន ចុះក្នុងសភាពក្រីក្រតោក យ៉ាកយ៉ាងឆាប់រហ័ស។ បើកុំ

www.elibraryofcambodia.org

គិតអ្វីឱ្យហួសមាឌប៉ុនប៉ងស្វែងរកផលប្រយោជន៍ ឱ្យសម ទៅនឹងសមត្ថភាពសេចក្ដីទីទ័លក្រ មុខជាមិនមកក្បែរខ្លួន អស់លោកអ្នកឡើយ ។

គោលសំខាន់នោះ គ្រប់គ្នាត្រូវចេះចាយវាយឱ្យ មានកំរិត និងសមធួនល្មមតាមកម្លាំង ( ទាំងកាយនិងវិជ្ជា របស់ផងខ្លួន) ស្រឡាញ់សិទ្ធិឥស្សរភាពយ៉ាងខ្ជាប់ខ្ជួន ចូរ ប្រកាន់យកសុភាសិតដែលថា "អត្តាហិអត្តនោនាថោ" ខ្លួនជាទីពឹងរបស់ខ្លួន កុំរំពឹងទៅលើតែអ្នកដទៃ មាន ឈ្មោះថាជាមនុស្ស បើមិនចេះស្គាល់ប្រមាណ ហើយគិត រំពឹងទៅលើតែអ្នកដទៃ រហូតនោះចូរកុំសង្ឃឹមថានឹងបាន ជួបប្រទះ នឹងសុភមង្គលក្នុងជីវិតឱ្យសោះ !

ពាក្យថា "រំពឹងអ្នកដទៃ" មិនបានសំដៅដល់មាតា បិតា ឬចៅហ្វាយនាយនោះទេ តែជាពាក្យសំដៅដល់ការ ពឹងពាក់ពុំនាក់អាស្រ័យមនុស្សជាទូទៅ ។ នៅក្នុងគ្រា ដំបូងនោះ ជាការធម្មតាទេ ដែលចាំបាច់ត្រូវតែពឹងពាក់ ពុំនាក់អាស្រ័យអ្នកដទៃ តែកុំទៅគិតពឹងគេរហូតអស់

www.elibraryofcambodia.org

មួយជីវិត ។ យើងត្រូវព្យាយាមធ្វើខ្លួនរបស់យើងឱ្យបានទៅជាទីពឹងរបស់យើងជានិច្ច ។ ការពឹងពាក់គ្នាដោយមានថ្នូរគេមិនហៅថាពឹងទេ ។

តែទោះបីជាយ៉ាងនោះក៏ជានាទីដែលយើង ត្រូវតែគិតដល់បុណ្យគុណរបស់គេ អ្នកដែលឱ្យពឹងនោះតាមសមគួរ។ អ្នកខ្លះប្រកាន់ថាមានបងប្អូនមិត្តភ័ក្តិច្រើន មិនគិតខំធ្វើការរកស៊ីទេ ចូលចិត្តដើរទៅខ្ជីបុលគេចាយសប្បាយហ៊ឺហាជារឿយៗមនុស្ស ប្រភេទនេះគេហៅថាមិនចេះស្រឡាញ់សិទ្ធិឥស្សរភាព ចាត់ទុកនៅក្នុងជំពូកពឹងអ្នកដទៃដោយចំ ។

ពិតមែនថាយើងត្រូវធ្វើការងារទទួលប្រាក់ខែរបស់អ្នកដទៃមកចិញ្ចឹមជីវិត ប៉ុន្តែ. បើការងារនោះប្រព្រឹត្តទៅដោយសមត្ថភាពរបស់យើង ដោយប្រាកដក៏អាចហៅថា យើងពឹងខ្លួនរបស់យើងបានដែរ តែគេចាត់បញ្ចូលទៅក្នុងជំពូកកណ្តាល ពីព្រោះការធ្វើជាកូនឈ្នួលគេ រមែងពុំសូវបានស្រួលដូចជាយើងប្រកបមុខរបរដោយខ្លួនឯង

www.elibraryofcambodia.org

ឡើយ ។ ការដែលខ្ញុំនិយាយបែបនេះ មិនមែនកាត់ផ្តាច់ផ្លូវមិនឱ្យអស់លោកអ្នកធ្វើការងារ ដើម្បីស្វែងរកប្រៀវត្សមកចិញ្ចឹមជីវិតទេ ធ្វើចុះការងារដើម្បីប្រាក់ខែនោះ បើវាជាការងារដែលសមសួន នឹងសមត្ថភាពរបស់យើង ។ ប៉ុន្តែបើបានធ្វើហើយមិនត្រូវ ឈប់នឹកនាពីអនាគតដោយគិតខ្លីៗថា អញប៉ុណ្ណេះលែងស្លាប់ ហើយមិនបាច់ខ្វាយខ្វល់រកការងារដទៃទៀតបំរុងទុកទេ ចុះឧបមា ថាគេលែងត្រូវការប្រើយើង ឬកិច្ចការរបស់គេនោះត្រូវបិទ ទ្វាររលំរលាយអស់ទៅ ពេលនោះយើងត្រូវអត់ការធ្វើជាស្វ័យប្រវត្តិ តើយើងមិនត្រូវស្លាប់ឈរទៅហើយ?

មនុស្សគ្រប់រូបត្រូវតែបោះជំហានទៅមុខជានិច្ច ! កុំគិតថយក្រោយ តែត្រូវបោះជំហានឱ្យទៅតាមលំដាប់ថ្នាក់ដោយប្រើវិចារណញ្ញាណ ចេះបារម្ភទៅកាលខាងមុខការចេះ ស្ទាបស្ទង់ថ្លឹងខ្លួនឯងហ្នឹងហើយដែលសំខាន់ជាងគេ ។ កុំរវើរវាយគំនិតចាក់ស្មុគប៉ងប្រាថ្នាទៅលើរបស់ដែលនៅមិនអាចធ្វើបានកុំយកសេចក្តីហ៊ឺហា ខ្ជិលច្រអូស

www.elibraryofcambodia.org

មានក្របរបស់អ្នកដទៃ មកធ្វើជារង្វាស់រង្វាល់នឹងការងាររបស់យើងចូរធ្វើតែការងារ ណាដែលហុចមកតាមលទ្ធ-ភាពនៅចំពោះមុខ រួចហើយសឹមរកផ្លូវពង្រីកបោះជំហានជាលំដាប់តទៅ ។ ជាងគំនូរមិនអាចគូសវាសតែម្តង ឱ្យបានសំរេចទៅជារូបដ៏ត្រកាលយ៉ាងណា យើងក៏មិនអាចធ្វើឱ្យការងាររបស់យើងបានល្អទៅក្នុងថ្ងៃ តែមួយដូច្នោះដែរ ។

នៅមានគោលសំខាន់មួយ៉ាងទៀត គឺត្រូវធ្វើខ្លួនឱ្យទៅជាមនុស្សហ៊ានអារកាត់ កាលបើមានការអ្វីមកនៅចំពោះមុខ ត្រូវគិតហើយធ្វើភ្លាមកុំរារែក កុំចង់ធ្វើការដែលមិនទាន់មក ដល់វានឹងធ្វើឱ្យលោកអ្នកទៅជាមនុស្សរវើរវាយចាប់នេះ ចាប់នោះមិនឆ្ពោះត្រង់ណា ការងារដែលកំពុងធ្វើនោះនឹង ទៅជាខូចអស់ទៅបើហោចណាស់ក៏ធ្វើឱ្យលោកអ្នកត្រូវយឺត យ៉ាវជាងកាលវេលាដែលត្រូវបានសំរេចដែរ ។

ការដែលថាមនុស្សប្រាជ្ញាច្រើន មិនចេះស្តាប់ស្តង់

www.elibraryofcambodia.org

កម្លាំងរបស់ខ្លួននោះ រមែងហុចលទ្ធផលអាក្រក់ដល់ខ្លួន ឱ្យធ្លាក់ខ្លួនទៅជាក្រីក្រតោកយ៉ាកបានដោយងាយ ។ ខ្ញុំធ្លាប់បានជួបប្រទះមកជាច្រើនគ្នាហើយ ដូចមានឧទាហរណ៍មួយនៅស្រុកមោងឫស្សីខេត្តបាត់ដំបង ដែលជាស្រុកកំណើតរបស់ខ្ញុំតែម្តង ឈ្មោះសំឪពុកម្តាយជាអ្នកមានបង្គួរនៅក្នុងស្រុកមានស្រែភ្លឺជាច្រើន តែសំជាមនុស្សស្រឡាញ់ការហ៊ឺហានៅ ពេលទៅលេងក្រុងភ្នំពេញឃើញគេអ្នកក្រុងស្លៀកពាក់ឆើតឆាយ ស៊ីចាយឥតសំចៃ ក៏ចង់ធ្វើខ្លួនឱ្យបានដូចគេដែររហូត ដល់ទៅកាត់ចិត្តចាកចោលស្រុកកំណើតទៅនៅស៊ីឈ្នួលក្នុង ហាងជំនួញមួយ ដោយបានទទួលប្រាក់ខែមួយខែមួយពាន់ពីររយរៀល រហូតមកដល់ឥឡូវសំនៅតែរហាមខ្វះមុខខ្វះ ក្រោយដដែល គ្រាន់តែបានចំណេញមានឈ្មោះជាអ្នកក្រុង កំទេចកំទីនឹងគេម្នាក់ប៉ុណ្ណោះ តើចង់បានឈ្មោះជាអ្នកភ្នំពេញ បានប្រយោជន៍អី? បើប្រសិនជារស់នៅស្រុកកំណើតវិញ ផ្ទះនៅស្រាប់ស្រែភ្លឺមានធ្វើគ្រប់គ្រាន់ ក្នុងមួយឆ្នាំៗឃើញថា

www.elibraryofcambodia.org

បានទទួលផលពីស្រែចំការមិនតិចម៉ឺនទេ ឯការចាយវាយក៏តិចសភាពទីទ័លក្រក៏នឹងចេះតែរលប់រលាយអស់ទៅជាលំដាប់ តែការដែលសំទៅជាក្ររហេមរហាមកាន់តែខ្លាំងដូច្នោះ ក៏ព្រោះតែសេចក្តីប្រាថ្នាហួសមាឌ មិនចេះថ្លៃថ្លឹងប្រមាណខ្លួនហ្នឹងឯង។ ដូច្នេះពាក្យដែលថា "គ្រប់គ្នាមិនចង់ក្រ ប៉ុន្តែហេតុអ្វីបានជាក្រ" គឺមាននៅក្នុងន័យដូចបានពោលមកខាងដើមហ្នឹងឯង ។

ដោយករណីនេះ និងដោយន័យដូចដែលបានពោលមកខាងដើម មនុស្សគ្រប់រូបអាចកំចាត់សេចក្តីទីទ័លក្របាន ដោយអាស្រ័យគោលធម្មជាតិជាគ្រឿងជំនួយម្យ៉ាង ដោយជាអ្នកចេះស្ទាបស្ទង់ប្រមាណការដែលគួរមិនគួរទៀតផងម្យ៉ាង ទើបឆ្លងផុតពីសេចក្តី ទីទ័លក្របានដូចសេចក្តីប្រាថ្នា ។ ប៉ុន្តែ, បើនៅតែចចេសប្រព្រឹត្តនៅក្នុងផ្លូវដែលជំនះនឹងធម្មជាតិរៀងដរាបទៅហើយ ដរាបនោះ "បើទុកជាអស់លោកអ្នកមិនចង់ក្រក៏អស់លោកអ្នកនៅតែគេចពីសភាពទ័លក្រមិនផុតអស់មួយជីវិត" កាលបើបានជ្រាប

www.elibraryofcambodia.org

ជាហូរហែតាមន័យនេះ ហើយសូមអស់លោកអ្នកដែលសង្ឃឹមសេចក្ដីសុខ សេចក្ដីចំរើនដល់ខ្លួន ចូររំពឹងគិតរួចហើយ ពិចារណាទៅតាមផ្លូវដ៏គួរចុះ ។

www.elibraryofcambodia.org

# វគ្គទី២

# យើងត្រូវជំនោះទល់ដោយវិធីណា?

ពាក្យថា "ក្រ" មានន័យទៅបានយ៉ាងច្រើនប្រការ ដូចជាក្រមាសក្រប្រាក់ក្រតំរេះវិជ្ជាក្របងប្អូនញាតិមិត្ត ។ល។ និងក្រអ្វីៗជាច្រើនគរគោករដឹកទៀត កាលបើមិនមានហើយគេហៅថា "ក្រ" ពីព្រោះពាក្យថា "ក្រ" និង "មាន" រមែងជាគូនឹងគ្នា ។

នៅក្នុងជំពូកសេចក្ដីក្រទាំងឡាយ ដែលបានពោលមកហើយនោះ តើមានអ្វីឱ្យសំខាន់ជាជាងក្រ "តំរេះវិជ្ជា" គឺគ្មានពីព្រោះថា បើខ្វះវិជ្ជាមួយមុខហើយ ក៏នឹងបណ្ដាលឱ្យសេចក្ដីក្រក្នុងប្រការដទៃៗ ទៀតសណ្ដោងរយោងទៅតាមគ្នាដែរ ។ ដោយប្រការដូចនេះហើយ មនុស្សដែលខ្លាចចំពោះសេចក្ដីក្រគួរស្វាត់ស្វែងរកតំរេះវិជ្ជា ទុកឱ្យនៅជាគោលប្រចាំខ្លួនជាបឋម ។

www.elibraryofcambodia.org

សូមកុំភ័ន្តច្រឡំពាក្យថា "វិជ្ជា" នៅក្នុងទីនេះ មិនមែនសំដៅទៅលើតែវិជ្ជាក្បួនលេខនព្វន្ត ឬអក្សរទេ ការចេះដឹងការមានសមត្ថភាពគ្រប់បែបយ៉ាង គឺសុទ្ធសឹងតែជាវិជ្ជាទាំងអស់ ។ ការជាជាងឈើ ជាងគំនូរ ជាងសូនរូបជាងលាប ថ្នាំ ជាងម៉ាស៊ីន ជាងដេរ។ ការលីសែង ការប្រដាល់ទាំងអស់នេះ សុទ្ធសឹងតែវិជ្ជាដោយឡែក១ពីគ្នា ។ ការធ្វើមុខធ្វើមាត់ និងនិយាយធ្វើឱ្យគេឯងបានសើចក៏ជាវិជ្ជាមួយមុខដែរ វិជ្ជាទាំងអស់នេះសុទ្ធតែធ្វើឱ្យកើតបានជាលុយកាក់ ។ កាលបើមិនក្រវិជ្ជាលុយកាក់ក៏មិនក្រដែរ វាជាស្រមោលអន្ទោលទៅតាមខ្លួន ។

ប៉ុន្តែ, ពាក្យថា "សេចក្តីក្រ" នោះ ស៊ីន័យធំទូលំទូលាយណាស់ ដូច្នេះចាំបាច់ត្រូវតែកំរិតសេចក្តីក្រឱ្យទៅជាថ្នាក់៧សិន ទើបអាចអធិប្បាយពាក្យថាសេចក្តីក្របានល្អិតល្អន់គឺ ÷

១- សេចក្តីក្រសំរាប់អ្នកមានបុណ្យសក្តិធំដុំឧត្តុង្គឧត្តម ខ្ញុំបំរើឆ្វេងស្តាំ ជំពូកដែលមានចំណូលច្រើនរាប់បាន

www.elibraryofcambodia.org

ថាជាអ្នកមានឯការចំណាយច្រើនតិច គឺទៅតាមសភាព។ កាលបើមានឱនភាព ខាងមុខចំណូលបន្តិចបន្តួចត្រឹមតែខ្វះខាតមួយរយៈពេលក៏គេហៅថា "ក្រ" ដែរ ។

២- សេចក្តីក្រសំរាប់ពពួកអ្នកជំនួញម្ចាស់គ្រឹះស្ថានធំៗ និងសេដ្ឋី ជនជំពូកនេះមានចំណូលបានជាប្រាក់បង្វិល និងប្រាក់ដេក កាលបើការជួញប្រែលក់មិនសូវដាច់ មានការខ្វះខាតប្រាក់បង្វិល រហូតដល់ដកប្រាក់ដេកមកធ្វើជាប្រាក់ចំណាយគេក៏ហៅថា "ក្រ" ដែរ ។

៣- សេចក្តីក្រសំរាប់ពលរដ្ឋសាមញ្ញ ដែលមានមុខរបររកស៊ីខាងធ្វើស្រែធ្វើចំការនិងលក់ដូរតូចតាចកំប៉ិកកំប៉ុក កាលបើមាន ការខ្វះខាតប្រហែល ១ឆ្នាំដូចជាតម្លៃស្រូវអង្ករ ចុះថោករបស់លក់មិនសូវដាច់ ក៏គេហៅថា "ក" ដែរ ។

៤- សេចក្តីក្រសំរាប់ស្មៀនស្មេរ អ្នកធ្វើការនិងពពួកកម្មករដែលមានចំណូលបានត្រឹមមួយខែគ្រប់មួយខែប៉ះចំលើ ខែណាចាយលុយចាស់អស់មុនលុយថ្មីបើកបានក៏គេហៅថា "ក្រ" ដែរ ។

www.elibraryofcambodia.org

ប៉ុន្តែ សេចក្ដីក្ររបស់មនុស្ស ៣ជំពូកដំបូងដែល បានពោលរួចមកហើយនោះ នៅហៅថាសេចក្ដីក្រដ៏ពិត ប្រាកដមិនទាន់បានទេ ត្បិតអីបើទុកជាគេក្រ ក៏គេនៅ មានសង្ហារិម ទ្រព្យនឹងសង្ហារិមទ្រព្យដទៃៗទៀតជាច្រើន ទោះបីជាមានការខ្វះខាតក៏ត្រឹមតែមួយរយៈ ប៉ុណ្ណោះមិន ដល់ថ្នាក់ក្រអត់អង្គរស្ងោរទេ ហើយមនុស្សជំពូកនេះ ច្រើន តែមិនសូវអើពើ នឹងសភាពការរស់នៅរបស់មនុស្សថ្នាក់ ទាបទាល់តែសោះ ទុកណាជាមានមធ្យោបាយជួយលើក ស្ទួយមនុស្សថ្នាក់ទាបបានខ្លះ ក៏គេមិនរវល់យកចិត្តទុក ដាក់ដែរ រីឯសេចក្ដីក្ររបស់មនុស្ស ជំពូកទី៤ នោះក៏មិន សូវជាសំខាន់ណាស់ណាដែរ ពីព្រោះបើ ទោះបីថា ប្រាក់ ខែនេះនិងវាមុខមិនជួបគ្នាក៏មែនពិត តែក៏ជាវេលាមិន បានប៉ុន្មានថ្ងៃដែរ បន្តិចប្រាក់សំរាប់ខែថ្មីក៏នឹងបាន មក ទើបនៅមិនទាន់ហៅថាក្រមែនទែនទេ ។

សំរាប់មនុស្សដែលគ្មានការងារធ្វើ ហើយត្រូវ ទទួលភារៈចិញ្ចឹមមាតាបិតាចាស់ជរា ឬប្រពន្ធកូននេះ

www.elibraryofcambodia.org

ទើបហៅថាក្រពិតប្រាកដ។ ប្រភេទរកព្រឹកស៊ីល្ងាចចាត់ថានៅគ្រាន់ដោះស្រាយប្រភេទរកព្រឹក ស៊ីព្រឹក រកល្ងាចស៊ីល្ងាចនេះបានចំជាលំបាកភ្លាត់ស្នៀតរកមិនបានក៏ត្រូវដាច់ពោះតែម្តង ។ ខ្ញុំធ្លាប់បានប្រទះឃើញមកជាច្រើនគ្នាហើយជូនកាលរហូតដល់ទៅ អួលដើមកព្រោះតែអាណោចអាធ័មចំពោះមនុស្សជំពូកនោះ ដែលមានថ្ងៃខ្លះ គេនាំគ្នាបរិភោគអាហារត្រឹមតែមួយពេល ប៉ុណ្ណោះ គឺពេលល្ងាចដែលជាពេលដ៏ចាំបាច់ត្បិតអីបើបរិភោគ ពេលព្រឹកអស់ទៅពេលល្ងាចដែលជាពេលសំខាន់នឹងមុខជាអត់ ។

ខ្ញុំធ្លាប់បានឃើញផ្ទាល់ភ្នែករួចមកហើយ វណ្ណៈអធនរបស់យើងនៅមានចំនួនច្រើនណាស់ អ្នកខ្លះគ្មានការងារធ្វើដល់ទៅពីរឆ្នាំ ត្រូវទ្រាំរស់ក្នុងអន្លង់ទុក្ខសោកយំមិនចេញទឹកភ្នែក តើបើរបៀបនេះឱ្យយល់ថាដូចម្តេចឱ្យមនុស្សយើងខំ ស្វះស្វែងរកប្រកបមុខរបរតែក្នុងផ្លូវសុចរិតរៀងរហូតទៅឬ? ទេ ! សូមលោកអ្នកកុំយល់ដូច្នោះបញ្ហាក្រពះធំណាស់មិន ថារូបយើងរូបគេ កាលបើ

www.elibraryofcambodia.org

ទឹកចូលដល់ច្រមុះហើយ គេនឹងមិនព្រមដេកអត់បាយស្លាប់ជាដាច់ខាត ! ពេលនោះបុរសត្រឹម ត្រូវនឹងក្លាយទៅជាជនអាវ៉ាសែ ចេះបោកប្រាស់ចេះលួចប្លន់ស្ត្រីវិញនិងក្លាយទៅជាអ្នកលក់បរវេណី (ពេស្យា) ទាំងនេះ គឺបណ្តាលមកតែពីសេចក្តីក្រមួយមុខហ្នឹង ។

ក្នុងជំពូកជនទីទ័លក្រទាំងនេះ មិនមែនថាជាមនុស្សទុព្វលភាពទៅទាំងអស់ក៏ទេដែរ ជាចំនួនច្រើនដែលមានទាំងកម្លាំងកាយ និងចំណេះវិជ្ជា ប៉ុន្តែមិនអាចនិងរកការងារធ្វើបាន ដោយគ្មានច្រកចូល គ្មានអ្នកជួយឧបត្ថម្ភពីព្រោះការរក ការងារធ្វើក្នុងពេលសព្វថ្ងៃនេះ បើគ្មានបក្សពួកហើយកុំសង្ឃឹមថា នឹងបានដូចសេចក្តីប្រាថ្នាឱ្យសោះអ្នកណាៗ ក៏គេចង់ឱ្យបក្សពួកគេបានការងារធ្វើដែរ គ្មានអ្នកណាយកអ្នកក្រៅទៅចូល ទេ សូមឱ្យគិតមើលចុះមិនថាការងារណា ឬក្រសួងណាទេ ឱ្យតែមានផ្លាស់ប្តូរនាយចៅហ្វាយម្តងៗ អ្នកណាដែលមិនមែន បក្សពួកគេត្រូវតែដកខ្លួនចេញ ឯខាងបក្សពួកគេត្រូវចូលមកកាន់

www.elibraryofcambodia.org

ម្តងនេះជារឿងពិត ។ កុំថាឡើយតែការងារនៅគ្រឹះស្ថានធំៗ ឬក្រសួងនីមួយៗ សូម្បីតែការងារនៅតាមរោងល្ខោន ឬតាមផ្ទះលក់កាហ្វេគុយទាវក៏មានលំនាំតែមួយដូចគ្នានេះដែរ ។

ដោយប្រការដូចបានពោលមកនេះហើយ ទើបខ្ញុំសំរេចចិត្តចងក្រងជាក្បួនដោះទ័លក្រនេះឡើង ដើម្បីចាផ្លូវរិះគិត របស់អស់លោកអ្នកដែលនៅងឿងឆ្ងល់ពីរឿងក្រប្រសើរជា ជាងខំដកកស្វះស្វែងរកការងារធ្វើពីអ្នកដទៃ ដែលជាសេចក្តីសង្ឃឹមដូចសង្ឃឹមផ្កាយលើមេឃ ។ ខ្ញុំមានជំនឿថារាល់គ្នា ដែលគ្មានការងារធ្វើ ហើយតាំងចិត្តពិតៗនឹងកំចាត់សេចក្តី ទីទ័លក្ររបស់ខ្លួននោះ គឺមានផ្លូវនឹងកំចាត់បាន បើប្រសិនជាអស់លោកអ្នកប្រតិបត្តិតាមគោលនៃក្បួនដោះទ័លក្រនេះ មួយរយៈពេល ។ ប៉ុន្តែសូមឱ្យយល់ថាក្បួននេះសរសេរ ឡើងដើម្បីដោះទ័លក្រត្រឹមតែមួយរយៈពេលតែប៉ុណ្ណោះ ដែលជាគំនិតដើមរបស់ខ្ញុំ គឺមិនបាច់ទៅអង្វរករអ្នកដទៃ យើងក៏នៅមាន

www.elibraryofcambodia.org

បាយស៊ី មានផ្ទះជ្រកមានគ្រឿងតុបតែងលំអទី លំនៅស្មើមុខស្មើមាត់នឹងគេមានពេលបានដើរលេងកំសាន្ត លំហែចិត្តតាមកាលសម័យ ជាពលរដ្ឋដ៏សាមញ្ញម្នាក់ នឹងឱ្យទៅជាឆើតឆាយរហូតដល់ថ្នាក់មហាសេដ្ឋីក៏ទេដែរ ។

ឯគោលសំរាប់ដោះទ័លក្រនោះ មិនជាការពិបាកអ្វីឱ្យណាស់ណាទេ បើប្រសិនជាយើងជាមនុស្សមានកម្លាំងពលំមាំទាំមិនទុព្វលភាព ទោះបីជារកការងារធ្វើមិនបានយើងក៏នៅអាចដោះទ័លក្របានដោយខ្លួនរបស់យើង ពីព្រោះស្រុកយើងមានក្រសួងសង្គមកិច្ច និងការងារដែលសំរាប់ជួយលោកអ្នករកការងារឱ្យបានធ្វើ ។

ប៉ុន្តែគោលដំណោះទ័លដោយខ្លួនឯងតាមក្បួនរបស់ខ្ញុំនោះ ត្រូវប្រកាន់ភ្ជាប់ក្នុងគោលធម៌ច្រើនប្រការគឺ ÷

១- ប្រកាន់ខ្ជាប់នូវសេចក្តីស្មោះត្រង់ ។

២- លះបង់ការអៀនខ្មាស់ចោល ។

៣- ត្រូវធ្វើឱ្យទៅជាមនុស្សមានទឹកចិត្តអង់អាច ។

៤- កុំមានគំនិតថយក្រោយ ។

www.elibraryofcambodia.org

៥- បញ្ហាខ្លួនឯងឱ្យបោះជំហានទៅមុខជានិច្ចទាំង ៥ប្រការនេះហើយជាគោលធមិដ៏សំខាន់អាចជួយឱ្យ ធ្វើការដោះទ័លក្របាន ដូចសេចក្តីប្រាថ្នា ហើយចូរយល់ថា ការដោះទ័លក្រនោះ នឹងដំណោះបានត្រឹមត្រូវតាមភារៈនៃគោលធមិរបស់ លោកអ្នកនឹងប្រព្រឹត្តទៅប៉ុណ្ណោះ បើអ្នកប្រព្រឹត្តនោះមានឋានៈខ្ពស់ លក្ខណៈការដំណោះទ័លក្រ ក៏ចេះតែពង្រីកខ្លួនចេញទៅដែរ តាមចំណែក ។

១- ការប្រកាន់ខ្ជាប់នូវសេចក្តីស្មោះត្រង់មានន័យទូលំទូលាយគឺ ÷

ក- ត្រូវស្មោះត្រង់ចំពោះមិត្តភ័ក្តិរួមការងារជាមួយ

ខ- ស្មោះត្រង់ចំពោះពេលវេលានៃម៉ោងធ្វើការងារ

គ- ស្មោះត្រង់ចំពោះខ្លួនរបស់យើង ។

២- លះបង់ការអៀនខ្មាសចោល បានសេចក្តីថា យើងមិនត្រូវអៀនខ្មាសក្នុងអំពើដែលយើងធ្វើហើយដោយសច្ចធមិ ប៉ុន្តែត្រូវអៀនខ្មាសចំពោះអំពើអាក្រក់ ។ មិនអៀនខ្មាសចំពោះអំពើល្អផ្តោតចិត្តឱ្យនឹងនកុំរវល់គិតថា÷

www.elibraryofcambodia.org

ក- យើងមិនធ្លាប់ធ្វើការរបៀបនេះមកពីមុន ។

ខ- មនុស្សម្នាក់នេះយើងមិនធ្លាប់ទៅរកគេ ។

គ- យើងគប្បីទៅរកការងារដែលសក្តិសមនឹងឋានៈរបស់យើងវិញប្រសើរជាង ។

បើយើងនៅរវល់តែគិតឃើញរបៀបនេះ តឱ្យមួយសែនជាតិទៀត ក៏ដោះទ័លក្រដែលគ្របដណ្តប់លើឋានៈរបស់លោកអ្នកមិនរួចដែរ ។ លោកអ្នកចាំបាច់ត្រូវធ្វើគ្រប់យ៉ាងនៅក្នុងការងារដែលសុចរិត លោកអ្នកត្រូវព្យាយាមទាក់ទងរកមនុស្សដែលធ្វើប្រយោជន៍ ឱ្យដល់ការងារ ឬការលក់ដូររបស់លោកអ្នក ។ យើងទៅសុំការគេធ្វើ ឬទៅនិយាយលក់ដូរទំនិញឱ្យដល់គេក៏ទុកដូចជាយើងយកប្រយោជន៍ទៅឱ្យគេដែរ វាជាថ្នូរគ្នាទៅវិញទៅមក ចាំបាច់ទៅខ្មាសអៀន ឬខ្លាចគេធ្វើអ្វី ។ បើយើងទៅលួចឆក់គេនោះ គួរយើងមានការខ្មាសអៀនក្នុងពេលក្រតោកយ៉ាក យើងមិនត្រូវរើសការងារទេ ការងារណាដែលបានឱ្យមកចំពោះមុខ គឺការងារនោះជាការងារដ៏ល្អ

www.elibraryofcambodia.org

របស់យើងហើយ យើងត្រូវកាត់ចិត្តកាត់ការខ្លាសអៀន អោនមុខធ្វើមួយគ្រាសិន រួចហើយសឹមរកបោះជំហានតទៅមុខទៀត ។

៣- ត្រូវធ្វើឱ្យទៅជាមនុស្សមានទឹកចិត្តអង់អាចបានសេចក្ដីថា ត្រូវក្លាហានក្នុងផ្លូវដែលនាំឱ្យខូចប្រយោជន៍របស់អ្នកដទៃ ដោយមានគោលជាគ្រឿងត្រិះរិះដូចតទៅនេះ គឺ ÷

ក- បើយើងចង់បានកុំខ្លាចបង់ កុំខ្លាចខាតដើមក្នុងការងារដែលប៉ុនប៉ងទុក ។

ខ- ត្រូវហ៊ានចូលទាក់ទងរកមនុស្សដែលអាចមានប្រយោជន៍ដល់កិច្ចការរបស់យើង ។

គ- ការងារណាដែលបានពុះពាររមកហើយ ទោះបីមានឧបសគ្គចូលមករារាំង ត្រូវតែហ៊ានធ្វើឱ្យចប់ចុងចប់ដើម។ ពាក្យថាឱ្យទៅជាមនុស្សមានទឹកចិត្តអង់អាចនេះក៏គឺសំដៅឱ្យទៅជាមនុស្សចិត្តពិត១ហ្នឹងឯង ។

៤- កុំមានគំនិតថយក្រោយ ជាគោលតឿនចិត្តឱ្យ

www.elibraryofcambodia.org

កើតសេចក្តីមានះក្នុងកិច្ចការងារ ទោះបីការងារនោះជាការងារប្រភេទណាក៏ដោយ កាលបើបានសំរេចចិត្តហើយត្រូវចាប់ផ្តើមធ្វើភ្លាម កុំរវល់គិតអល់អែកថា ÷

ក- ជាការងារធ្ងន់ធ្ងរពេក ។

ខ- ខ្លាចក្រែងបានផលកំរៃតិច ។

គ- រង់ចាំរកការងារដែលងាយស្រួលចំណេញច្រើនប្រសើរជាង ។

ការគិតដូច្នេះ នឹងធ្វើឱ្យជីវិតរបស់លោកអ្នកត្រូវអាប់អួរ ពីព្រោះសេចក្តីទីទ័លក្រចូលមកគ្របដណ្តប់អស់មួយជីវិត។

៥- បញ្ចាខ្លួនឯងឱ្យបោះជំហានទៅមុខជានិច្ច គឺកាលបើបានប្រតិបត្តិតាមគោលធម៌ទាំង ៤ ខ ខាងដើមមករហូតបានស្រួលបួលឃើញថាដើរត្រូវផ្លូវមែនទែនហើយត្រូវព្យាយាមបញ្ចាខ្លួនឯងឱ្យបោះជំហានទៅខាងមុខជាប់ជានិច្ច កុំឱ្យត្រឡប់ក្រោយបែរបោះជំហានទៅខាងមុខដើម្បីស្វែងរក សេរីភាពសុភមង្គលសុខសាន្តក្នុងជីវិត ។

www.elibraryofcambodia.org

ទោះបីនៅក្នុងការ បោះជំហានដំបូង ត្រូវលំបាកហត់នឿយ ក៏ត្រូវតែទ្រាំសិន រួចហើយលទ្ធផលល្អនឹងមកតបស្នងយើងវិញនៅពេលក្រោយជាពុំខាន ។ ចូរព្យាយាមកុំនឹកគិតដល់របស់ដែលទៅហួសរួចមកហើយ វានឹងធ្វើឱ្យដួងចិត្តដ៏បរិសុទ្ធរបស់លោកអ្នកស្ថិតស្រពោនចុះជាលំដាប់ ។

កាលបើបានប្រតិបត្តិតាមនេះហើយ សេចក្តីទីទ័លក្រទាំងអំបាលម៉ាន នឹងពុំមានលទ្ធភាពចូលមកគ្របដណ្តប់លើឋានៈរបស់អស់លោកបានតទៅទៀតឡើយ ។

www.elibraryofcambodia.org

# វគ្គទី៣

# សេចក្តីពេញចិត្តក្នុងកិច្ចការងារ ជាផ្លូវនៃសេចក្តីសុខ

នៅក្នុងវគ្គទី២ ខ្ញុំបានពោលដល់ការដំណោះទ័លក្រ ថានឹងធ្វើបានដោយវិធីដូចម្តេច? ជួនកាលនឹងធ្វើឱ្យអស់លោកអ្នកមានការគិតឆ្ងល់ថាតាំងតែពីដើមរហូតដល់ចុងវគ្គ មិនឃើញមានប្រាប់លក្ខណៈនៃការរកលុយសោះ ហេតុអ្វីទើបថា បានពោលដល់វិធីនៃការដោះទ័លក្រទៅកើត? បើអស់លោកអ្នកមានការងឿងឆ្ងល់សង្ស័យដូច្នោះមែន ចូរយល់ជាថ្មីថា: "ការរកលុយនោះមិនជាការពិបាកអ្វីឡើយ" កាលបើប្រតិបត្តិបានតាមគោលធមិទាំង៥ប្រការ ដូចដែលបានពោលនៅក្នុង វគ្គទី២ នោះហើយ ។ លោកអ្នកនឹងលូកដៃទៅកាន់អ្វីចាប់អ្វី ទៅក៏នឹងកើតបានជាលុយជាកាក់ទាំងអស់ សូមឱ្យតែតាំងចិត្តថាធ្វើបែបតែ

www.elibraryofcambodia.org

ប៉ុណ្ណាគ្រប់គ្រាន់ ទោះបីជានៅក្នុងកាលៈទេសៈ នេះស្រុកយើងកើតសង្គ្រាម ដែលអ្នកណាៗគេនាំគ្នាស្រែកយំមិនចេញទឹកភ្នែកថា "សេដ្ឋកិច្ចធ្លាក់ដល់បាតដាល" ក៏យើងនៅមានផ្លូវរកលុយកាក់ចិញ្ចឹមជីវិតបានដែរ ។

អំពីរឿងសេដ្ឋកិច្ចធ្លាក់ដល់បាតដាលនេះ ខ្ញុំនៅមានការងឿងឆ្ងល់នៅឡើយ ត្រង់ធ្លាក់មែនឬមិនមែន សូមឱ្យអស់ លោកអ្នកយកទៅពិចារណាខ្លួនឯងផងចុះ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំឃើញថា ទោះបីជាសេដ្ឋកិច្ចមានឱនភាពក៏មាននៅតែក្នុងចំណោមប្រជាជន រីឯតាមរោងភាពយន្តរោងល្ខោន ភោជនីយដ្ឋាន បារ កន្លែងទាំងអស់នេះដូចជានៅមិនទាន់ធ្លាក់សោះ ផ្ទុយទៅវិញ. ឃើញកាន់តែកុះករច្រើនឡើង ។

សូម្បីគោលធម៌ ៥ប្រការ ដែលបានពោលមកខាងដើមជាអង្គគុណសំរាប់ជួយឱ្យលោកអ្នកបានសំរេចមគ្គផលនៃការដោះទ័លក្រក៏មែនពិត ប៉ុន្តែនៅមិនទាន់ច្បាស់តែងណាស់ណាដែរ ពីព្រោះនៅមានគុណសម្បត្តិម្យ៉ាងទៀត

www.elibraryofcambodia.org

ដែលអាចជួយឱ្យលោកអ្នកផុតពីសេចក្តីទីទ័លក្រ លុះត្រា សំរេចលទ្ធផលក្នុងកិច្ចការបានស្រួល ហើយរហ័សទៀត របស់នោះ គឺកិត្តិគុណកេរ្តិ៍ឈ្មោះដោយលោកអ្នកត្រូវធ្វើខ្លួនជាអ្នកបណ្តុះជំនឿឱ្យដល់មនុស្សទូទៅ ឬមនុស្សដែលលោកអ្នកត្រូវការទាក់ទងជាមួយ កុំគិតថាយើងជាអ្នកក្រគ្មានផ្ទះថ្មសសរស្តម្ភ អ្នកណា គេមកជឿយើង? បើគិតយ៉ាងនោះគឺជាគំនិតដែលខុសធំតែម្តង ការជឿចិត្តរាប់អានរវាងគ្នានិងគ្នា វាស្ថិតនៅត្រង់ទឹកចិត្តមិនទាក់ទងជាមួយលំនៅស្ថានឬឋានៈទេ។ បើយើងជាមនុស្សទៀងត្រង់ម៉ាត់ណាម៉ាត់ហ្នឹងហើយ អ្នកណាៗគេក៏ត្រូវតែជឿរាប់អានយើងគ្រប់គ្នា ។ ក្រៅពីនេះថាមានម្យ៉ាងទៀត គឺការសេពគប់សមាគមកាន់តែទូលំទូលាយបានគឺកាន់តែល្អ ពីព្រោះការស្វែងរកមុខរបរដោយឯកឯងនោះ សំខាន់នៅត្រង់ដែលស្គាល់មនុស្សច្រើន ហើយបើសិនជាមុខរបរនោះ ជាប់ទាក់ទងទៅនឹងផ្សារទំនិញផងក៏កាន់តែប្រសើរខ្លាំងណាស់ទៅទៀត ។

www.elibraryofcambodia.org

ប៉ុន្តែនៅមានសំខាន់ម្យ៉ាងទៀត គឺលោកអ្នកត្រូវកំណត់ក្នុងចិត្តខ្លួនឯងថា មនុស្សយើងត្រូវស្វែងរកច្រកផ្លូវដើម្បីមុខរបររកស៊ី ឯមុខរបររកស៊ីនោះ លោកអ្នកមិនគប្បីជ្រើសរើសតាមទំនើងចិត្តចង់របស់លោកអ្នកទេ កុំឃើញថា យកគំរូតាមគេជារបសល្អ ទោះជាការងារអ្វីក៏ដោយ បើជាការងារដែលមានមនុស្សធ្វើតិច ការងារហ្នឹងហើយល្អ ទោះបីយើងមិនពេញចិត្តថា គ្រាដំបូងក៏ខំធ្វើឱ្យពេញចិត្តឡើង ពីព្រោះសេចក្តីពេញចិត្តក្នុងកិច្ចការងាររមែងជាផ្លូវនាំឆ្ពោះ ទៅកាន់សេចក្តីសុខដែលខ្ញុំហ៊ានពោលដូចនេះ ព្រោះការងារគ្រប់បែបយ៉ាង បើពេញចិត្តហើយឱនមុខធ្វើមែន ក៏រមែងផ្តល់លទ្ធផលដល់អ្នកធ្វើជាដរាប ! សូមកុំឱ្យតែការងារនោះ ដែលលំអៀងទៅក្នុងផ្លូវទុច្ចរិត ពីព្រោះបើទុកជាមានលទ្ធផលល្អនៅគ្រាដំបូងតែវាក៏អាចនឹងត្រឡប់មកជាអាក្រក់វិញបាននៅពេលក្រោយ ។

www.elibraryofcambodia.org

# វគ្គទី៤

# គ្រប់គ្នាសុទ្ធតែមានសេរីភាព ស្មើគ្នាទាំងអស់

ខ សំខាន់ដែលនឹងដំណើរការប្រកបមុខរបរឱ្យបាន ទៅជាលទ្ធផលល្អនោះ យើងត្រូវធ្វើខ្លួនឱ្យទៅជាមនុស្ស មានចិត្តថ្លើមនឹងន ស្ថិតនៅក្នុងសភាពជាធម៌ (ច្បាប់រដ្ឋ) របស់ក្រុមទេសមិនបាច់ភ័យ បារម្ភចំពោះអ្វីៗ កាលបើ មិនមែនជាកំហុស ។ យើងជាខ្មែរស្ថិតទៅក្នុងច្បាប់រដ្ឋ ខ្មែររដ្ឋធម្មនុញ្ញបានផ្តល់សិទ្ធ គឺការស្មើភាគដល់យើង ហើយ ត្រូវយើងប្រាកដក្នុងចិត្តជានិច្ច "មនុស្សគ្រប់រូបមានឥស្សរ ភាពស្មើគ្នាទាំងអស់" កាលបើគិតបានដូចនេះនឹងធ្វើឱ្យ ការងាររបស់យើង បានប្រព្រឹត្តស្រួលដោយប្រការទាំង ពួង ព្រោះធ្វើឱ្យយើងជាមនុស្សក្លាហានចំពោះអំពើដែល គប្បីក្លាហានតទៅ ។

www.elibraryofcambodia.org

ការទៅសុំការងារគេក្តី ការទៅធ្វើទំនាក់ទំនងក្តី មិនគួរក្រែងរអែងចិត្ត ឬខ្មាសអៀនចំពោះអ្នកដែលយើងត្រូវចូលទៅប្រឈមមុខជាដាច់ខាត។ អ្នកខ្លះច្រើនក្រែងថា "ចូលទៅសុំការគេធ្វើ វែកងគេនឹងពេបជ្រាយថាជាមនុស្សចោលម្សៀតគ្មានការងារធ្វើ" សូមកុំខ្លាចក្រែងអ្វីឱ្យសោះ ព្រោះតែយើងអត់ការធ្វើហ្នឹងហើយ ទើបបានជាយើងទៅសុំការងារគេធ្វើបែរជាគិតឃើញផ្ទេសផ្តាស ដូច្នេះក៏ទុកដូចជាគេបាន សំដែងនូវសេចក្តីទាបថោកនៅក្នុងដួងចិត្តឱ្យលេចចេញមកបង្ហាញដល់ខ្លួនគេតែម្តង បើយើងជាមនុស្សចោលម្សៀត យើងនឹងហ៊ានចូលទៅសុំការងារពីគេធ្វើបានដែរឬ? មនុស្សម្នាក់ៗ ត្រូវតែមានការងារធ្វើគ្រប់គ្នា ការងារជាថ្នូរសំរាប់ដូរយកផលប្រយោជន៍ពីគ្នាទៅវិញទៅមកគ្មានចាំបាច់ត្រូវគិតញាប់ញ័រអ្វីទាល់តែសោះការសុំទានគេត្រង់ៗទៅវិញទេ ដែលយើងត្រូវខ្មាសអៀនមែនទែន ។ ខ្ញុំធ្លាប់ឃើញយុវជនក្រមុំកម្លោះជាច្រើនប្រព្រឹត្តខ្លួនជាអ្នកសុំទាន ទាំងផ្លូវត្រង់និងផ្លូវកាត់នាំឱ្យ

www.elibraryofcambodia.org

វេទនាភ្ញាក់យ៉ាងខ្លាំង មធ្យោបាយរកលុយនៅមានច្រើនទៀត ហេតុអ្វីទើបគេបែរជានាំគ្នាយល់ឃើញខុសជាត្រូវក្នុងការយកក្រពះទៅផ្ញើជាមួយអ្នកដទៃ ដោយគ្មានថ្នូរយ៉ាងនេះទៅវិញ?

ខ្ញុំពោលបែបនេះ សូមលោកអ្នកកុំយល់ថា ខ្ញុំនិយាយឱ្យរួចតែពីមាត់ ប៉ុន្តែមិនឃើញមានប្រាប់ពីវិធីរកលុយឱ្យសោះវាជាការ ចាំបាច់ដែលមិនអាចលាតត្រដាងនៅក្នុងទីនេះបាន ពីព្រោះវិធីរកលុយមានច្រើនណាស់ បើនឹងយកមកបរិយាយ ហើយដប់ទំព័រក្រដាសក៏មិនគ្រាន់ផងទើបបានត្រឹមតែ បង្ហាញនូវគោល៧និងគោលធមិទុកឱ្យលោកអ្នកដែលត្រូវការ កំចាត់សេចក្តីទីទ័លក្រយកទៅពិចារណាដោយខ្លួនឯង។ ប៉ុន្តែទុកជាដូច្នេះក្តី លោកអ្នកក៏គប្បីទទួលដឹងឮ ទុកជាគោល៧បន្តិចផងចុះថា បណ្តាសព្វសារពើទាំងឡាយទៅក្នុងសកលប្រថពីភាគនេះ សុទ្ធសឹងតែត្រូវមានធម្មជាតិសាងសន្សំទុកទាំងអស់ បើយើងចេះនាំគ្នាគិតប្រឌិតហើយសព្វវត្ថុទាំងនោះ ក៏នឹងក្លាយទៅជា

www.elibraryofcambodia.org

លុយបានដោយស្រួល សូមឱ្យតែប្រជាជន ទាំងឡាយតាំងចិត្តមែនប៉ុណ្ណោះមុខជាសំរេចលទ្ធផលល្អប្រសើរគ្រប់ប្រការ ។

www.elibraryofcambodia.org

# វគ្គទី៥

## ចូរព្រមក្រកាយ
## តែកុំព្រមក្រចិត្ត

សេចក្ដីអត់ឃ្លានក្ររមែងជារបស់ដែលមនុស្សគ្រប់រូបចាំបាច់ត្រូវភពប្រសប់គ្រប់ៗគ្នា បើនឹងមានប្លែកត្រង់ក្រតាមឋានៈរបស់គេនឹងយើងប៉ុណ្ណោះ។ ដោយហេតុនេះទើបខ្ញុំសរសេរជាក្បួនដោះទ័លក្រនេះឡើងដើម្បីគ្រាន់ទុកជាផ្លូវត្រិះរិះរបស់លោកអ្នកទាំងឡាយ ទៅតាមអត្តភាព។

ចូរលោកអ្នកកាត់ចោលចេញនូវទំនើងចិត្តឡឹតលយឆាយ រួចត្រូវឱ្យចេះលៃប្រមាណខ្លួនដូចដែលបានពោលរួចមកហើយខាងដើមចុះ លោកអ្នកមុខជាមិនជួបប្រទះនូវសេចក្ដីទីទ័លក្រឡើយ។ សេចក្ដីសុខកាយសប្បាយចិត្តមិនបានស្ថិតនៅត្រង់អ្នកមានសម្បត្តិទ្រព្យវាល់កោដិលាននោះទេ ការសង់ផ្ទះតូចៗ ឬជួលកូនបន្ទប់មួយតូចនៅ

www.elibraryofcambodia.org

ដោយមានមុខចំណូលបានល្មមសមគួរ ក្រោយពីកាត់មុខចំណាយចេញរួចស្រេច ក៏ចាត់ទុកបានថាជាសេចក្ដីសុខគ្រប់គ្រាន់នឹងអត្តភាព។ ប៉ុន្តែឥឡូវនេះមនុស្សយើងមិនដូច្នោះឯណា សូម្បីតែនៅមិនទាន់ដល់គ្រាក្រផងក៏រត់ត្រសុលចូលទៅរកសេចក្ដីក្រខ្លួនឯង បើតែយ៉ាងនេះ តើនឹងទៅបន្ទោសអ្នកណា ។ ចំពោះពពួកកម្លោះៗ ឥឡូវនេះគឺ បារ កុន ល្ខោន ល្បែង។ល។ និង។ល។ ទាំងអស់ហ្នឹង ហើយដែលចាំកន្ត្រាក់ឱ្យធ្លាក់ចូលទៅក្នុងរណ្ដៅក្រ បើអ្នកណាភ្លាត់ស្នៀត គឺមុខជាគ្មានទឹកភ្នែកសំរាប់យំ ។

ចូរមនុស្សគ្រប់រូបចងចាំទុកថា កាលបើយើងអាចដោះស្រាយរឿងក្របានក្នុងថ្ងៃនេះ យើងក៏អាចនឹងមានទៅបាននៅថ្ងៃមុខ ត្រង់ឱ្យមនុស្សយើងក្រអស់មួយជីវិតនោះ គឺមានតិចណាស់ ប៉ុន្តែទោះបីជាគ្រាដែលក្រ ក៏កុំសុខចិត្តឱ្យ ក្រទាល់តែរលីងធេងអស់ពីខ្លួនឱ្យសោះត្រូវបន្សល់ទុកខ្លះ គឺ "ចូរព្រមក្រកាយ តែពុំព្រមក្រចិត្ត"

www.elibraryofcambodia.org

ទោះបីជាត្រូវជួលផ្ទះ គេនៅ ១ខែ ៥០០ រៀល ស៊ីមួយពេលអត់មួយពេលខោអាវ ប៉ះបំណះក៏ចូរឱ្យវាក្រតែកាយបានហើយ ឯចិត្តចូរកុំព្រមក្រត្រូវកែខៃនៅពេលខាងមុខនឹងព្យាយាមជាប់ជានិច្ច ។ ចិនមកពីស្រុកចិនមានសម្បត្តិធម្មជាតិជាប មកនឹងខ្លួនប៉ុណ្ណោះ នៅអាចធ្វើខ្លួនគេឱ្យទោជាអ្នកមានបាន ចុះយើងខ្មែរជាម្ចាស់ស្រុកផង តើត្រូវសុខចិត្តឱ្យអាប់ឱនជាងជនបរទេសទៅកើត ដែរឬ? ត្រូវយើងធ្វើចិត្តឱ្យរឹងឱ្យសមជាខ្មែរម្ចាស់ស្រុកផ្លូវណា ដែលសុចរិតត្រូវរត់តំរង់ចូលទៅចុះ មិនក្រយូរទេអស់លោក ! លោកអ្នកដើរកុំដើរអត់ប្រយោជន៍ កុំដេកអត់ប្រយោជន៍ កុំស៊ីអត់ប្រយោជន៍ត្រូវគិតទៅដោយបញ្ញាការ គិតអាចកើតឡើងនៅពេលដេកក៏មាន បើសុខចិត្តក្រចិត្តថែមទៅទៀត ប្រមជាមួយរាងកាយដែលត្រូវសេចក្តីទីទ័ល ក្ររុករានទន្រ្ទានស្រាប់ហើយ ចូរកុំសង្ឃឹមឱ្យសោះថានឹងមានឱកាសបើកភ្នែក ហារមាត់បានសមបំណង ។ ទោះបីជាក្រីក្រលំបាកលំបិនដូចម្តេចត្រូវខំ ធ្វើមុខឱ្យស្រស់ស្រាយ

www.elibraryofcambodia.org

ជាប់ជានិច្ចកុំអាលទុក្ខសោកធ្វើមុខស្អុយបែ  វានាំធ្វើឱ្យសេចក្ដី  សង្ឃឹមដែលប៉ុនប៉ងទៅមុខត្រូវរលំរលាយទៅជាមួយផង  មិត្តអ្នកនិពន្ធដើងចាស់របស់ខ្ញុំម្នាក់ធ្លាប់បានដាស់តឿនខ្ញុំថា ចូរឃំនៅតែដើមទ្រូងបានហើយ កុំបញ្ចេញមកខាងក្រៅនេះគឺ  បានសេចក្ដីថា  "កុំព្រមឱ្យក្រចិត្ត" ហ្នឹងឯង ។

លោកអ្នកដឹងទេថា  ខោទ្បាញ់ដាច។ដែលបោះចោលគ្មានអ្នកណារើស តែអ្នកជំនាញក្នុងការដោះទ័លក្រគេអាចធ្វើឱ្យវាក្លាយទៅជាប្រាក់បាន  ពីរបីរយក្នុងវេលាតែមួយភ្លែត។  នេះគ្រាន់តែជាការដាស់តឿននិងបង្ហាញគោល។ឱ្យអស់លោក  អ្នកចេញទៅប្រយុទ្ធក្នុងការដោះទ័លក្រប៉ុណ្ណោះ  អស់លោកអ្នកអានហើយវិនិច្ឆ័យឱ្យម៉ត់ចត់ចុះនឹងបង្កើតផលបានជា  បង្គួរដល់ខ្លួនលោកអ្នកជាពុំខាន ។

www.elibraryofcambodia.org

# វគ្គទី៦
# ការចេះមែនធ្វើមែនក៏ជាផ្លូវដោះទ័លក្របានដែរ

តាមដែលខ្ញុំបានពោលរួចមកហើយនៅវគ្គមុននោះ ឃើញថា នៅមិនទាន់គ្រប់គ្រាន់ទេ ហេតុនេះទើបត្រូវរែកញែកបន្ថែមបន្តិចទៀត នៅក្នុងវគ្គនេះដើម្បីឱ្យអស់លោកអ្នកបានយល់កាន់តែច្បាស់មែនទែន ។ ចំពោះវគ្គមុនៗបានពោលបរិយាយរួចហើយថា ការចេះដឹងនូវវិជ្ជាផ្សេងៗនោះ គឺសុទ្ធសឹងជាថ្នាំកែរោគក្របានទាំងអស់ តែនៅមិនទាន់បានកំរិតឱ្យបានច្បាស់លាស់នៅឡើយ ។ អ្នកខ្លះស្គាយយកចំណេះវិជ្ជា ទុកម៉ាសន្ទីកតែនៅតែដោះពីរឿងទ័លក្រមិនរួច ក៏តាំងមកអង្គុយថ្លែងសារទុក្ខថា "យ៉ាប់មែនគ្នាខំរៀនមកសព្វសារពើធ្វើការងារបានគ្រប់យ៉ាងតែក៏នៅចៀសក្រមិនផុត" ការពោលរបៀបនេះ

www.elibraryofcambodia.org

តើលោកអ្នកខ្លួនឯងមានបានគិតពិចារណាឱ្យសព្វគ្រប់ហើយ ឬនៅថា នៅក្នុងមុខវិជ្ជាទាំងអំបាលម៉ានមួយមុខៗ លោកអ្នកជាអ្នកចេះដឹងមែនមិនមែនគ្រាន់តែចេះ របៀបកោកសឹកមាត់ត្រដោក ឆ្អែតពោះក្របីទេឬ? ខ្ញុំខ្លាចក្រែងថា នៅមិនចេះឱ្យពិតប្រាកដឡិតអី បើលោកអ្នកប្រាកដជាចេះសព្វគ្រប់មែនហើយ "លោកអ្នកពិតជាដោះខ្លួនរួច" ដូចសុភាសិតបុរាណពោលថា ចេះអ្វីចេះឱ្យប្រាកដចេះ នៅក្នុងផ្លូវអត់ចេះប្រសើរជាង ។ ដូច្នេះការដែលលោកអ្នកយិតយោងខ្លួនមិនរួច ក៏ប្រហែលជាបណ្ដាមកពីលោកអ្នកចេះមិនទាន់ប្រាកដហ្នឹងឯង ។

រីឯយោបល់របស់ខ្ញុំក្នុងផ្នែកឯកទេសនោះ នៅមានបំណងនឹងពោលជំទាស់បន្តិចទៀតថា តាមសុភាសិតចាស់បុរាណដែលបានស្ដីនោះ នឹងថាមែនក៏បានមិនមែនក៏បាន ដោយមានដំណោះស្រាយក្នុងការជំនាន់ដូចតទៅនេះ គឺ ÷

១- ដែលថាមែន ពីព្រោះសម័យបុរាណ ភាគច្រើន

www.elibraryofcambodia.org

ច្រើនរអើលនឹងអ្នកមានចំណេះវិជ្ជា ថែមទាំងគ្មានការប្រកាន់បក្សប្រកាន់ពួកថែមទៀត គឺស្រេចតែថា អ្នកណាល្អក៏ទទួលយកចិញ្ចឹមដោយមិនរើសមុខ ឧទាហរណ៍ដូចយ៉ាងលោកតាក្រមង៉ុយគាត់គ្រាន់តែជាជនសាមញ្ញម្នាក់ ហើយក្រីក្រទៀតផង ក៏នៅមានផ្លូវដោះខ្លួនរួចដោយអាស្រ័យវិជ្ជាច្រៀងខ្សែ ដៀវរបស់គាត់ ។

២- ដែលថាមិនមែន ដោយហេតុថាសម័យនេះជាសម័យវិទ្យាសាស្ត្រ មិនមែនសម័យបុរាណសុភាសិតបុរាណស្ទើរតែប្រើការលែងកើតអស់ទៅហើយ ដូច្នេះសុភាសិតបុរាណពោលទុកទើបមិនអាចយកជាការពិតទាំងអស់បាន ។ ឧទាហរណ៍មនុស្សដែលមានចំណេះវិជ្ជាស្មើគ្នា បានប្រាក់ខែ មិនស្មើគ្នា ឬម្នាក់បានការធ្វើតែម្នាក់ ទៀតអត់ការធ្វើទាំងនេះបណ្ដាលមកពីអ្វី? សូមលោកអ្នកល្បងគិតមើលខ្លួនឯងទៅចុះ ។

ណ្ហើយ ! ទោះជាដូចម្ដេចក្ដី យើងក៏គួរប្រកាន់យកគោលសុភាសិតបុរាណ ទុកមួយអន្លើសិន បើឃើញ

www.elibraryofcambodia.org

ថាប្រើការមិនកើតសឹមបណ្ដោយទៅតាមសាច់រឿង ពី-ព្រោះបើទុកជាមិនបានល្អគ្រប់ ដប់ក៏គង់មិនដល់ធ្លាក់ដល់ថ្នាក់សូន្យដែរ ការចេះដឹងពិតប្រាកដនឹង ជាឱសថកែរោគក្រឱ្យលោកអ្នកបានអស់មួយជីវិត ។ ប៉ុន្តែខ្ញុំសូមខ្សឹបដាក់រន្ធត្រចៀកលោកអ្នកថា គួរកត់ត្រាទុក "វិជ្ជាបញ្ចោរ" ទុកនៅក្នុងតារាងមេរៀន របស់លោកអ្នកផងកាន់តែប្រសើរវានឹងទៅជាថ្នាំកែរោគក្រ ឆុតឆាប់សក្ដិសិទ្ធិជាទីបំផុត ។

ខ្ញុំបាទមិនចង់និយាយអ្វីឱ្យវែងឆ្ងាយជាងនេះទៀតទេ ប៉ុន្តែចាំបាច់ត្រូវតែនិយាយតទៅ ព្រោះតាមគោលដែលដាក់ថា ចេះអ្វីចេះឱ្យប្រាកដអាចកែរោគក្របាននោះពិតមែនវាជាពាក្យស៊ីគ្នានឹង សុភាសិតបុរាណបានយ៉ាងជិតស្និត ប៉ុន្តែវាជំទាស់នឹងក្បួនរបស់ខ្ញុំខ្លះ ស្របគ្នាខ្លះ ។ ក្បួនរបស់ខ្ញុំនេះ ស្មោះត្រង់ចំពោះការណែនាំឱ្យបុគ្គលចេះរកការដោះទ័លក្រ តែខំក្នុងកិច្ចការងារដែលនឹងបង្កើតបាន ជាមុខរបររបស់ខ្លួន តែមួយមុខមិនបានគិតទៅដល់

www.elibraryofcambodia.org

ការងារថ្នាក់ទាបថ្នាក់ខ្ពស់តែ យ៉ាងណាឡើយ រីឯសុភា-សិតដែលថា "ចេះអ្វីចេះឱ្យប្រាកដ" នោះ ច្រើនសំដៅយកការងារថ្នាក់ខ្ពស់ គឺថាបើភ្លាត់ចំណាប់ ហើយនឹងធ្វើឱ្យអ្នកនោះដាំដូងសំយុងក្បាលធ្លាក់ចុះក្នុងរណ្តៅក្របានយ៉ាងឆាប់រហ័ស ពីព្រោះចុងបញ្ចប់ក៏ត្រូវបែរទៅអនុវត្តន៍ទៅក្នុងគោលការដោះទ័លក្ររបស់ខ្ញុំទៅទៀត ។ ដោយប្រការដូចនេះ ហើយពាក្យថាចេះអ្វីចេះឱ្យប្រាកដ ទើបគប្បីឈប់សំរាកនៅត្រឹមហ្នឹងសិន ព្រោះជាសុភាសិតដែលហាក់ដូចជាខ្វាស់គ្នានឹងក្បួននេះយ៉ាងច្រើន ។

តាមយោបល់យល់ឃើញរបស់ខ្ញុំបូកផ្សំជាមួយនឹងគោលធម្មតាទាំងឡាយ សាកលនិករទាំងពួងត្រូវតែជាមនុស្សដែលគ្រប់គ្រាន់ទៅដោយចំណេះវិជ្ជា ដោយប្រការទាំងពួងឥតរើសមុខ គ្រាន់តែថាបើមានឱកាសហុចឱ្យសិក្សាបានហើយ គប្បីត្រូវសិក្សាទុកជាដើមទុនមិនរើសមុខ កាលបើដល់ពេលអាសន្នអន់ក្រចំណេះវិជ្ជា ដែលមាន

www.elibraryofcambodia.org

ជាដើមទុនហ្នឹងហើយនឹងជួយស្រោចស្រង់ខ្លួនយើងឱ្យផុតពីរណ្ដៅក្របានសមបំណង ។

សូម្បីរូបខ្ញុំអ្នកសរសេរក្បួននេះ ជាមនុស្សធ្លាប់មានបានរួចម្ដងមកហើយក៏មែនពិត តែក្នុងពេលឥឡូវនេះ ខ្ញុំក៏គឺអ្នកក្រហ្នឹងឯង ។

ខ្ញុំធ្លាប់ក្ររួចមកហើយក្រ១ស្ទើរតែគ្មានកន្ទបវ័ណ្ឌតែ ដោយខ្ញុំបានប្រកាន់យកគោលតាមដូចដែលបានពោលមកហើយខាងដើម សេចក្ដីទីទ័លក្រក៏ចេះតែរលប់ចេញពីឋានៈម្ដងបន្តិច១ជាលំដាប់ ប៉ុន្តែទុកថាដូច្នោះក្ដី ខ្ញុំសព្វថ្ងៃក៏គង់ស្ថិតនៅក្នុងសភាវៈក្រដដែល ។

សូមជឿខ្ញុំចុះ សេចក្ដីទីទ័លក្រមិនអាចមានអំណាចខ្លាំងក្លាធ្វើសេចក្ដីវិនាសឱ្យយើងបានរហូតទេ បើប្រសិនជាយើងស្គាល់នូវ ឫសកែវរបស់វាកើតពីអ្វីឱ្យច្បាស់ ។ តាមគោលសាសនានិងធម្មតានិយម "ការខ្ជិលច្រអូស" ហ្នឹងហើយជាឫសកែវនៃសេចក្ដីក្រ ទោះបីជាមានចំណេះវិជ្ជាចេះដឹងប៉ុណ្ណា តែបើមានសេចក្ដីខ្ជិលច្រអូសជាម្ចាស់ចិត្ត

www.elibraryofcambodia.org

គឺមុខជាមិនអាចគេចផុតពីសេចក្ដីទីទ័លក្របានទេ ដូច្នេះលោកអ្នកគប្បី បណ្ដេញសេចក្ដីខ្ជិលច្រអូសឱ្យចេញពីរាងកាយរបស់លោក អ្នកយ៉ាងឆាប់រហ័សបំផុត ។

www.elibraryofcambodia.org

# វគ្គទី៧
# គន្លឹះពិសេសសំរាប់ការ
# ដោះទំលក្រ

នៅក្នុងវគ្គទី៥ បានពោលជាស់តឿនរួចហើយថា ចូរ ព្រមក្រកាយ តែកុំព្រមក្រចិត្ត ។ នោះជាគោលដ៏ជាក់ច្បាស់សំរាប់មនុស្សគ្រប់រូបត្រូវតែប្រតិបត្តិតាម ពីព្រោះជាគោលការតែមួយគត់ ដែលនឹងធ្វើឱ្យលោកអ្នកទៅជាមនុស្សក្លាហានមិនរុញរាចំពោះសេចក្តីទីទ័លក្រ និងមកភពប្រសប់តាមធម្មតានោះមនុស្សយើង បើកាន់តែធ្វើចិត្តឱ្យស្រពាប់ស្រពោនប៉ុណ្ណា សេចក្តីទីទ័លក្រកាន់តែរុករានរាតត្បាតខ្លាំងឡើងប៉ុណ្ណោះដែរ ។ បើយើងធ្វើចិត្តឱ្យរីករាយជាប់ជានិច្ចជាកាល ទោះបីជាទីទ័លខ្វះខាតខ្លះក៏នៅតែគ្រាន់បើត្បិតអីផ្ទៃមុខ យើងនៅស្រស់បស់ល្អមនឹងចូលទៅរកអ្នកនេះអ្នកនោះបានដោយងាយស្រួល ។

www.elibraryofcambodia.org

ការធ្វើចិត្តឱ្យស្រស់ញញឹមមិនសោកសៅនៅក្នុងគ្រាក្រនោះ គឺជាការដ៏ ប្រសើរបំផុត ដូចដែលបានពោលរួចមកហើយនៅខាងដើម ប៉ុន្តែយើងត្រូវតែស្រាវជ្រាវរាវរកគំនិត គិតដល់វិធីរកលុយឱ្យខ្លួនយើងបានចាយខ្លះពីព្រោះវាជាការ ដោះទ័លក្របានមួយគ្រាដែរតែការរកលុយនោះមានល្បិច តិកនិកច្រើនបែបច្រើនយ៉ាង។ យើងត្រូវជ្រើសរើសឱ្យបាន ប្រពៃទើបជាការងាយស្រួល ។ ខ្ញុំនឹងពោលត្រឹមតែ ២-៣ វិធីសំរាប់ក្បួនដោះទ័លក្រនេះគ្រាន់ជាពាក្យណែនាំឱ្យអស់ លោកអ្នកទៅជាមនុស្សក្លាហាន ដើម្បីអាចប្រតិបត្តិតាមក្បួនបង្វិលលុយប៉ុណ្ណោះតែទុកជាដូចម្តេចក្តី ខ្ញុំមានជំនឿថា អាចផ្តល់ប្រយោជន៍ឱ្យដល់លោកអ្នកទាំងឡាយ ដែលយកចិត្តទុកដាក់បានជាបង្គួរ ។

ប៉ុន្តែ សូមយល់ឱ្យច្បាស់ថា ការប្រតិបត្តិខ្លួនដើម្បីការដោះទ័លក្រនោះ សូមលោកអ្នកកុំប្រតិបត្តិឱ្យទៅជាប្រយោជន៍បៀតបៀនមុខរបររបស់អ្នកដទៃបាន គឺកាន់

www.elibraryofcambodia.org

តែប្រសើរមែនទែន ព្រោះនៅក្នុងវេលាសព្វថ្ងៃនេះតាមដែលបានសង្កេតឃើញរួចមកហើយ ការប្រតិបត្តិខ្លួនដើម្បីការដោះទ័លក្រច្រើនតែចូលទៅក្នុងផ្លូវបៀតបៀនមុខរបរអ្នកដទៃដោយភាគច្រើន ។ វាជាលទ្ធិដែលទាបថោកខ្លាំងណាស់លក្ខណៈដែល នឹងបង្ហាញឱ្យឃើញថា ជាការបៀតបៀនមុខរបររបស់អ្នកដទៃនោះ គឺមានដូចតទៅនេះ ÷

១- ឃើញគេរកស៊ីអ្វីបាន យើងតាំងប្រកបមុខរបរដូចគេដែរ តែលក់ឱ្យថោកជាង ។

២- ឈ្លានពានញុះញង់ឱ្យអ្នកដែលគេទាក់ទងគ្នាមុន បែកបាក់ស្អប់ខ្ពើមគ្នា ។

៣- ដឹងថាគេនឹងធ្វើអ្វី យើងដណ្ដើមធ្វើរបស់នោះមុន ។

លក្ខណៈ ៣ ប្រការនេះជាលក្ខណៈអាក្រក់ទាបថោកមែនហើយពាក្យដែលថាការរកស៊ី ស៊ីសងអ្នកណាលឿនជាងវ័យជាងអ្នកនោះឈ្នះ តែថាវាជាការខូចសេចក្ដីបរិសុទ្ធ

www.elibraryofcambodia.org

នៃដួងចិត្តម្យ៉ាងដែល សុភាពជនមិនគប្បីយកមកអនុវត្តន៍ទាល់តែសោះ ។ ត្បិតអីវិធីដោះស្រាយរឿងទ័លក្រ ដែលល្មមនឹងចៀសរួចមិនឱ្យជាន់នឹងគេមានមួយតំនរប្រសិនជាមានជាន់ ត្មាក៏សូមឱ្យជាន់ដោយថៃដន្យកុំជាន់ដោយចេតនាអាក្រក់នោះ នឹងធ្វើឱ្យចិតលោកអ្នកមានសេចក្ដីសុខយ៉ាងច្រើន ។

នៅក្នុងសកលលោក មានសព្វសារពើវត្ថុទាំងឡាយអាចិកំបាំងជាច្រើន គឺថាបើយើងប្រើសេចក្ដីព្យាយាមយ៉ាងពិតប្រាកដឱ្យត្រឹមត្រូវតាមគោលឧស្សាហកម្មហើយសភាពនៃរបស់ទាំងនោះ ក៏អាចបណ្ដាលសេចក្ដីដោះទ័លក្រឱ្យសំរេចដល់យើងបានសមបំណង និងជួនកាលមិនត្រឹមតែដោះទ័លក្រប៉ុណ្ណោះទេ វាអាចធ្វើឱ្យលោក អ្នកកើតបានទៅជាសេដ្ឋីមួយដ៏តូចរួចក្លាយទៅជាមហាសេដ្ឋីនៅពេលដ៏មិនយូរប៉ុន្មាន ។

ស្រុកខ្មែរមានដីច្រើន តែមានមនុស្សតិច រីឯស្រុកដទៃៗទៀត ដូចជាស្រុកចិនមានមនុស្សច្រើនតែមានទីដី

www.elibraryofcambodia.org

តិចមិនគ្រប់គ្រាន់ ដល់ការប្រកបមុខរបរចិញ្ចឹមជីវិតជនជាតិចិន ទើបចាំបាច់ខ្នាត់ព្រាត់រង្គាត់ទៅនៅតាមប្រទេសដទៃទាំងនេះ ក៏ដើម្បីនឹងបោសរលាស់នូវសេចក្តីទ័លក្ររបស់ខ្លួនឱ្យ ជ្រះស្រឡះផុតទៅប៉ុណ្ណោះ ។ កាលបើជនជាតិចិនមកដល់ស្រុកខ្មែរ គ្រាន់តែបានជាន់ដីខ្មែរភ្លាមក៏ស្រែកថា "អញមិនក្រស្រេចទៅហើយយ៉ាងនេះបានសេចក្តីថាដូចម្តេច? គេជាមនុស្សខ្នាត់ព្រាត់មកពីចម្ងាយសោះគេអាចធានាបានដោយសុទ្ធចិត្តថាគេមិនក្រ តែហេតុអ្វីជនជាតិខ្មែរ ដែលកើតនៅស្រុកខ្មែរ ទើបមិនគិតដល់ទីដីដ៏ទមនេរធំល្វឹងល្វើយទាំងនោះ ខ្លះរវល់តែនាំគ្នារអ៊ូថាក្រៗទាល់តែទៅជាមេសូត្ររត់មាត់ រួចហើយក៏តាំងអង្គុយឱបក្បាលជង្គង់ធ្វើភ្នែកភ្លឹះៗសង្ឃឹមឱ្យ ទេវតាជួយទៅវិញ? ការឧស្សាហកម្មទាំងឡាយពួកយើងបណ្តោយឱ្យធ្លាក់ទៅនៅក្នុងកណ្តាប់ដៃពួកបរទេសអស់រលីង សូម្បីតែការងារធុនទាបដែលចំណាយដើម ទុនតិចដូចយ៉ាងលក់បបរ លក់ស្លាម្លូ ។ល។ នឹង ។ល។ ក៏ជារបស់ចិន

www.elibraryofcambodia.org

ការលក់ កាសែតក៏ជារបស់ចិនខ្មែរនោះមានតិចណាស់ ។ បើតែយ៉ាងនេះ ពួកយើងមកនាំគ្នារអ៊ូរទាំថាក្រៗនោះជាការសមរម្យហើយឬ?

នៅក្នុងទីដីទាំងឡាយ ទាំងពួងដ៏ទមនេរល្វឹងល្វើយហ្នឹងហើយ បើយើងចេះកែច្នៃនឹងឃើញថា សព្វវត្ថុដែលជាលុយជាកាក់បង្កប់ នៅគ្រប់ទីកន្លែងទាំងអស់ ។ ប៉ុន្តែមនុស្សខ្ជិលដេកចាំតែទេវតាដាក់ទាននៅក្នុងផ្ទះទេ ទើបមិនអាចមើលឃើញ ។

ខ្ញុំជាកូនខ្មែរ ខ្ញុំមិនចង់រិះគន់ជាតិសាសន៍ឯងទេ ប៉ុន្តែនៅក្នុងសេចក្តីយុត្តិធម៌ទាំងឡាយ ធម្មជាតិនៃការពិតបង្ខំឱ្យខ្ញុំចាំបាច់ត្រូវនិយាយថា ខ្មែរយើងនៅមានកំអែលនិស្ស័យជាមនុស្សខ្ជិលច្រអូសច្រើនគ្នាណាស់ បើប្រសិនជាអាចជំរុះក្អែលខ្ជិលច្រអូសទាំងនេះចោលចេញបាន ប្រទេសយើងនឹងបានទៅជាប្រទេសដ៏មុតមាំថ្កុំថ្កើងយ៉ាងឆាប់រហ័ស

សក្ខីកម្មនៃការមានបានដែលយើងអាចមើលឃើញបានពីជនបរទេស ដែលចូលមកពុះពារប្រកបការឧស្សាហ-

www.elibraryofcambodia.org

កម្ម ដោយមិនគិតពីសេចក្ដីខ្ជិលច្រអូស រួចគេក៏បញ្ជូនប្រាក់កាសយើងយកត្រឡប់ទៅស្រុកគេវិញ ឯយើងខ្មែរម្ចាស់ស្រុកបានត្រឹមតែអង្គុយមើល ឬបើមិនដូច្នោះក៏ធ្វើជាកូនឈ្នួលគេធ្វើ តែការងារកំប៉ិកកំប៉ុកគ្រាន់តែបានលុយកាក់យកទៅចិញ្ចឹម ក្រពះមួយថ្ងៃគ្រប់មួយថ្ងៃពុំបានគិតទៅដល់ផលនៃការមាន បានទៅថ្ងៃខាងមុខសោះ។ គេខំពុះពារព្យាយាមឱ្យយើង ឃើញតែយើងពុំបានធ្វើតាមគេសោះដូច្នេះជាការសមរម្យហើយឬ?

ការងារចេញមុខចេញមាត់របស់ខ្មែរយើងតាមដែលបានឃើញ ក៏គឺដាក់រានលក់ថ្នាំឬសឈើផ្ទះកាត់សក់ ។ល។ សុទ្ធសឹងជាមុខរបរតូចតាចកំប៉ិកកំប៉ុក រីឯការងាររបស់ជនជាតិបរទេស ដូចជាចិន បារាំង ដូចម្ដេចខ្លះសូមឱ្យគិតមើល? ទាំងនេះបណ្ដាលមកពីខ្មែរ យើងដែលមានលុយចូលចិត្តឱបលុយទុកមិនចង់ធ្វើអ្វី តែអ្នកដែលចង់ប្រកបមុខរបររកស៊ីត្រឡប់ជាគ្មានលុយទៅវិញ បើអ្នកមានលុយដែលមិនចង់ សាកល្បងប្រថុយឱ្យដើមដល់អ្នកដែល

www.elibraryofcambodia.org

ចង់រកស៊ីលមើលខ្លះ ជាការជួយលើកស្ទួយបងប្អូនរួមជាតិ ក៏ប្រហែលជានឹងបានឃើញថា ខ្មែរយើងក៏មិនអន់ជាងជនបរទេសដែរ ។ ការដែលខ្ញុំនិយាយមកនេះ សូមបងប្អូនរួមជាតិដែលមានលុយល្បងគិត មើលចុះមុខជានឹងឃើញផលល្អថា គួរមិនគួរដូចម្តេចសុភាសិតខាងផ្លូវសាសនាពោលថាកាលបើឃើញសេចក្តីសុខរបស់ គ្រួសារចូរលះបង់សេចក្តីសុខរបស់ខ្លួនចោលទៅ ហើយកាល បើឃើញសេចក្តីសុខរបស់មនុស្សទាំងស្រុកឬមនុស្សច្រើន ក្រុមចូរលះបង់សុខរបស់គ្រួសារចោលទៅ។ ដូច្នេះការដែលយើងឱ្យដើមទុនដល់អ្នកគ្មានដើមទុនប្រកបមុខរបរធំដុំដើម្បីកេរ្តិ៍ឈ្មោះរបស់ជាតិខ្មែរ ក៏មិនធ្វើឱ្យខូចបង់សេចក្តីសុខរបស់យើងប៉ុន្មានដែរ ពីព្រោះឧបមាថា យើងមានលុយដប់លានរៀល ឱ្យខ្ចីមួយលានរៀលជាការជួយផ្តុំផ្តើមទោះបីជាខាតដើមក៏មិនជាស្អី ទុកដូចថាយើងជួយលើកស្ទួយប្រទេសរបស់យើងទៅចុះ តែហេតុអ្វីក៏មិនគិត? ការដែលមិនគិតច្រើនៗគ្នានេះ ហើយធ្វើឱ្យប្រទេសខ្មែរ

www.elibraryofcambodia.org

យើងសំយុងក្បាល ធ្លាក់ចុះទៅរកសេចក្ដីក្រជាលំដាប់នាំឱ្យខ្ទាស់ដល់ប្រទេសដទៃៗ ដែលគេទើបតែដោះខ្លួនរួចពីនឹមទាសភាពយ៉ាងខ្លាំង ។

តាមដែលបានពោលមកនេះ គឺដើម្បីឱ្យទៅជាផ្លូវរិះគិត នៃបងប្អូនរួមជាតិគ្រប់គ្នាថា ការណាគួរណាមិនគួរដោយប្រការអ្វី ។ កាលបើឃើញថាជាការគួរ ក៏សូមឱ្យប្រញាប់រួសរាន់ជួយលើកស្ទួយគ្នា ដើម្បីសេចក្ដីរុងរឿងរបស់ប្រទេសយើងឱ្យចាកផុតពីសភាពក្របានឆាប់រហ័ស ។

រីឯអ្នកដែលស្ម័គ្រចិត្តជឿ ហើយត្រូវការស្វែងរកគោលសំរាប់ដំណោះស្រាយសេចក្ដីទ័លក្រនោះ ខ្ញុំសូមណែនាំបន្ថែមឱ្យជាពិសេសពីរប្រការទៀតគឺ ÷

១- ដំណោះទ័លក្រតាមធម្មតា

២- ដំណោះទ័លក្រដើម្បីសេចក្ដីមានបាន

ក- ដំណោះទ័លក្រតាមធម្មតានោះ ត្រូវប្រតិបត្តិតាមន័យដូចពោលរួចមកហើយខាងដើម កុំហក់លោតលយឆាយឱ្យខ្លាំងពេក លោកអ្នកមុខជានឹងចៀសផុតពីសេចក្ដីទីទ័លក្របានដូចសេចក្ដីប្រាថ្នា ។

www.elibraryofcambodia.org

ខ- ដំណោះទ័លដើម្បីសេចក្តីមានបាននោះ ត្រូវប្រើសេចក្តីព្យាយាមពុះពារចំពោះការឡើយហត់ បើគ្មានដើមទុនក៏ឡើយច្រើនបន្តិច មានដើមទុនក៏មិនសូវឡើយ និងបណ្តោះខ្លួនទៅកាន់ទីដីដ៏ល្វើងល្វើយមួយរយៈការ ឧស្សាហកិច្ចពីកសិកម្មនឹងធ្វើឱ្យលោកអ្នកមានបានតាមសេចក្តីប្រាថ្នា ។

បរិយាយមកក្នុងលក្ខណៈនៃការដោះទ័លក្រនេះ ដើម្បីគ្រាន់ជាផ្លូវត្រិះរិះដល់មហាជនទូទៅ បើប្រសិនជាមានភ្លាំងភ្លាត់ទៅត្រង់វគ្គឃ្លាណាមួយ សូមអស់លោករៀមច្បងអ្នកទ្រង់គុណវុឌ្ឍិពិសេស មេត្តាអភ័យទោសដល់ខ្ញុំអ្នករៀបរៀងតាមការគួរ ។

**ចប់ក្បួនដោះទ័លក្រ**

**ហាក់ ឆៃហុក**

www.elibraryofcambodia.org

# ពាក្យបរិយាយចុងក្រោយ

លោកអ្នកអានក្បួនដោះទ័លក្រមក តាំងពីដើមដល់ចប់ប្រហែលជានឹងគិតថា "ហ្នឹងឬក្បួនដោះទ័លក្រ មិនឃើញ ណែនាំរកផ្លូវអ្វីនាំឱ្យកើតបានជាលុយកាក់មួយមុខសោះ តើវានឹងដំណោះទ័លក្របានដូចម្តេច? បើលោកអ្នកគិតឃើញដូច្នោះ គឺខុសយ៉ាងធ្ងន់តែម្តង ពី-ព្រោះខ្ញុំបានពោលរួចមកហើយ នៅដើមដំបូងថា វាគ្រាន់តែជាក្បួនណែនាំបង្ហាញផ្លូវប៉ុណ្ណោះ សូម្បីតែចំណងជើងក៏បញ្ជាក់ស្រេចទៅហើយថា ក្បួនដោះទ័លក្រមិនមែនក្បួនរកលុយកាក់ឯណា?

បើសិនលោកអ្នកជ្រាបពីក្បួនរកលុយ តែនៅធ្វើខ្លួនរបស់លោកអ្នកឱ្យគ្រប់តាមអង្គគុណនៃការដោះទ័លក្រដែល ខ្ញុំបានប្រាប់ទុកហើយ ក្បួនរកលុយនោះក៏មិនមានប្រយោជន៍អីដល់លោកអ្នកដែរ ព្រោះថាក្បួនរកលុយដែលលោកអ្នកចង់បាននោះ មិនមានអង្គលក្ខណៈ

www.elibraryofcambodia.org

ឬក៏មូលដ្ឋានមាំទាំជាទីគួរឱ្យជឿជាក់មួយរយភាគរយនោះឡើយ ។ ខ្ញុំនិយាយដូច្នេះ លោកអ្នកប្រាកដជាពោលថា ឱ្យតែមានលុយអ្វីៗប្រាកដជា នឹងកើតមានជាពិតប្រាកដ ។ ការពោលដូច្នេះ ខ្ញុំទទួលស្គាល់ ថាត្រឹមត្រូវតែមួយភាគប៉ុណ្ណោះ ព្រោះថាអ្នកនិយាយពុំបានត្រិះរិះ និងគិតឱ្យបានជិតដល់ ដោយចាត់ទុកលុយជាចៅហ្វាយនាយជាម្ចាស់លើសិរសា ដែលខ្លួនត្រូវការគោរពបូជារៀងរាល់ទិវារាត្រីភ្លេចគិតថា វាជាប្រភពនៃសេចក្តីវិនាសដែរ ។

សុភាសិតបរទេសមួយពោលថា ÷

"ប្រាក់ជាបាវបំរើដ៏ល្អ, តែជាចៅហ្វាយនាយដ៏អាក្រក់" ។ ឆ្លងតាមរយៈសុភាសិតនេះ លោកអ្នកអាចឆ្លុះបញ្ចាំងឃើញពីក្បួនដោះទ័លក្ររបស់ខ្ញុំ និងក្បួនរកលុយដែលលោកអ្នកចង់បាននោះ តើមានលក្ខណៈខុសគ្នាយ៉ាងណា ហើយធ្វើការប្រៀបធៀបទៅ ប្រាកដជាលោកអ្នកនឹងយល់ជាក់ជាមិនខាន ។ មួយវិញទៀតការរំដោះខ្លួនពីភាពទ័លក្រមានន័យថា ធ្វើខ្លួនយើងឱ្យទៅជាប្រយោជន៍

www.elibraryofcambodia.org

របស់អ្នកដទៃ និងប្រទេសជាតិរបស់ខ្លួន ។ តាមគោលការណ៍សំខាន់ពីរគឺ ÷

១- ជួយឃើតយោងជនរួមជាតិដោយបន្តមុខរបរចិញ្ចឹមជីវិតរបស់គេ ។

២- ជាការជួយធ្វើឱ្យកេរ្តិ៍ឈ្មោះរបស់ខ្មែរកាន់តែប្រសើរឡើង ។

ការមានផលចំណេញច្រើន រមែងជាលទ្ធផលល្អសំរាប់ធ្វើជំនួញជួញប្រែ ប្រសិនចំណេញតិចយើងក៏នៅសប្បាយចិត្តថា បានជួយបងប្អូនរួមជាតិឱ្យមានការធ្វើគ្រាន់កំដរជីវិត ។

ខ្ញុំពោលដូចនេះ ព្រោះគោលសេចក្តីដែលពោលរួចមកហើយ ច្រើនជំពាក់ទាក់ទងនៅជាមួយនឹងក្បួនដោះទ័លក្ររបស់ខ្ញុំ។ សូមលោកអ្នកទាំងឡាយកុំជឿសំដីរបស់មនុស្សដែលថា វេលានេះសេដ្ឋកិច្ចធ្លាក់ដុនដាបនៅធ្វើអ្វីមិនទាន់បាន ការពិតគឺគេកំណាញ់ខ្លួនរបស់គេ ដើម្បីមិនត្រូវការឱ្យទៅជាប្រយោជន៍ដល់អ្នកដទៃ។ សេដ្ឋកិច្ចធ្លាក់ដុនដាបមែន ឬមិនមែនសូមលោកអ្នកអញ្ជើញទៅមើល

www.elibraryofcambodia.org

នៅតាមរោងភាពយន្តរោងល្ខោន ភោជនីយដ្ឋាននិងរង្គ-សាលម៉ាស៊ីនត្រជាក់ចុះ នឹងបានជ្រាបក្បោះក្បាយជាងការអធិប្បាយនៅក្នុងទីនេះ រីឯពួកជនបទអ្នកស្រែចំការគឺជាបញ្ហាមួយដោយឡែកទៀត ។

ចប់ដោយបរិបូណ៌

www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្មៅ យុនសំរ៉ង ខ្មៅ យ៉ាតណៃ ខ្មៅសុខផល ខ្មៅ វិសាល ខ្មៅ វ៉ាមុន ខ្មៅ ភាពដា ខ្មៅ ចំរើន ខ្មៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក **ខ្មៅ ពាញ** និង ឧបាសិកា **ឈរ យឿន**

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **ប្អូរ សេងទីន**

កញ្ញា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្មៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

www.elibraryofcambodia.org

ឡៀង ដានី

មានលក់ដុំ និងរាយ នូវសៀវភៅសិក្សា

គ្រប់ប្រភេទ ធម៌ ចំរៀង រឿងប្រលោមលោក

វចនានុក្រម ខ្មែរ អង់គ្លេស បារាំង ចិន · ថៃ

តូបលេខ 23 - 24 ផ្សាររុស្សី ជាន់ឡើងលើ

ទូរស័ព្ទលេខ 012 923 933

សូមអរគុណ !


www.elibraryofcambodia.org